# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០១ សរណ

## សារលិខិត
## សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី
## នៃរាជរដ្ឋាភិបាលកម្ពុជាថ្លែងក្នុងឱកាសទិវាអក្ខរកម្មជាតិ និងអន្តរជាតិ
## ៨ កញ្ញា ឆ្នាំ ២០០៧

*-សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ*

*-សម្តេច ទ្រង់ ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោកស្រី អស់លោក*

*-លោកសាស្ត្រាចារ្យ អ្នកគ្រូ លោកគ្រូ ក្មួយៗសិស្សា នុសិស្ស និងបងប្អូនជនរួមជាតិ ទាំងអស់ជាទីស្នេហា*

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និង ក្នុងនាមខ្ញុំព្រះករុណាខ្ញុំ ខ្ញុំសូមសំដែងនូវអំណរសាទរយ៉ាងក្លៀវក្លាជាមួយបងប្អូនជនរួមជាតិ លោកស្រី អស់លោក សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បុគ្គលិកសិក្សា ព្រមទាំងក្មួយៗសិស្សានុសិស្សទាំងអស់ ក្នុងទិវាអក្ខរកម្មជាតិ និង អន្តរជាតិ ៨ កញ្ញា ឆ្នាំ ២០០៧ នេះ។

ទិវាអក្ខរកម្មជាតិ និង អន្តរជាតិ ៨ កញ្ញា ជាទិវាមួយដែលមានអត្ថន័យឧត្តុង្គឧត្តមជាទីបំផុតសម្រាប់ប្រទេសជាតិយើង ក៏ដូចជាពិភពលោកទាំងមូលព្រោះ "អក្ខរកម្ម គឺជាគន្លឹះ ឬជាកូនសោនៃការអភិវឌ្ឍ" ជាភារកិច្ចចំបងចាំបាច់ មិនអាចខ្វះបានក្នុងការធ្វើឱ្យសម្រេចគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា និង ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ អភិវឌ្ឍប្រទេសជាតិមួយឱ្យរីកចំរើនបាន លុះត្រាតែយើងខិតខំអភិវឌ្ឍធនធានមនុស្សឱ្យប្រកបដោយចំណេះដឹង ចំណេះធ្វើ អាចពង្រីកខ្លួនក្នុងមជ្ឈដ្ឋានដែលខ្លួនរស់នៅ និង ចេះរួមរស់ក្នុងសុខសន្តិភាព។ ដើម្បីទទួលបានធនធានមនុស្សបែបនេះ គ្មានវិធីណាក្រៅពីការខិតខំផ្តល់សេវាអប់រំដល់ពលរដ្ឋគ្រប់វ័យ គ្រប់ភេទនោះឡើយ ហើយដែលក្នុងនោះ ការងារ អក្ខរកម្មគឺជាចំណុចចាប់ផ្តើម។ យើងអាចអភិវឌ្ឍប្រទេសជាតិបានឆាប់រហ័ស លុះត្រាតែយើងពង្រឹងសមត្ថភាពពលរដ្ឋ ដោយកាត់បន្ថយឱ្យបានច្រើនជាលំដាប់នូវអនក្ខរជន។

ខ្ញុំព្រះករុណាខ្ញុំ សូមរំលឹកឡើងវិញថា នាឱកាសទិវាអក្ខរកម្មជាតិឆ្នាំ ២០០៥ ខ្ញុំព្រះករុណាខ្ញុំ បានលើកឡើងពីយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ស្តីពីសាកលភាវូបនីយកម្ម នៃការអប់រំមូលដ្ឋាន ៩ឆ្នាំ ផ្សារភ្ជាប់ទៅនឹងអក្ខរកម្មវិជ្ជាជីវៈ ដែលមានខ្លឹមសារ ផ្តោតលើចំណុចពីរសំខាន់:

**ទីមួយ** : ធានាថា កុមារ និង មនុស្សពេញវ័យទាំងអស់ទទួលបានការអប់រំមូលដ្ឋាន ៩ ឆ្នាំដូចៗគ្នា ប្រកបដោយគុណភាព និង ស្មើភាព គ្មានការបែងចែក អំពីភេទ ជាតិសាសន៍ ឋានៈ និងវណ្ណៈអ្វីទាំងអស់។ រាជរដ្ឋាភិបាលផ្តល់អាទិភាពលើចំណុចនេះដោយជំរុញឱ្យមានសមធម៌យេនឌ័រក្នុងការសិក្សា ដោយខិតខំផ្តល់អាហារូបករណ៍ដល់កុមារីដែលឆ្លងភូមិសិក្សាពីថ្នាក់ទី៦ទៅថ្នាក់ទី៧ និង ដល់សិស្សក្រីក្រ ដើម្បីឱ្យពួកគេអាចបន្តការសិក្សាទៅមធ្យមសិក្សាទុតិយភូមិ ព្រមទាំងអាចបន្តការសិក្សាទៅឧត្តមសិក្សាទៀតផង។

**ទីពីរ** : ផ្សារភ្ជាប់ការងារអក្ខរកម្មទៅនឹងការអប់រំបច្ចេកទេសវិជ្ជាជីវៈសម្រាប់យុវជន និងមនុស្សពេញវ័យ ដែលជាសិស្សអក្ខរកម្ម ដើម្បីអាចយកទៅប្រើប្រាស់បានក្នុងជីវភាពប្រចាំថ្ងៃ ដូចជាបច្ចេកទេស កសិកម្ម ការចិញ្ចឹមសត្វ ការថែទាំសុខភាព ការអនុវត្ត តាមក្បួនអនាម័យ និង កិច្ចការពារទប់ស្កាត់ជម្ងឺផ្សេងៗ។ ចំណុចទាំងអស់នេះផ្តោតជាសំខាន់លើការកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋ ដោយយកការអប់រំធ្វើជាយុទ្ធវិធីដំបូងដើម្បីអភិវឌ្ឍប្រទេសជាតិ។

បន្ថែមពីលើចំណុចទាំងពីរខាងលើនេះ ជាទិសដៅសម្រាប់ការអនុវត្តបន្តទៅមុខទៀត ខ្ញុំព្រះករុណាខ្ញុំ សូមសង្កត់ធ្ងន់លើប្រធានបទសំខាន់សម្រាប់ឆ្នាំនេះគឺ "**អក្ខរកម្ម គឺជាសិទ្ធិមូលដ្ឋាន**" ដោយកំណត់ច្បាស់ថា "**អក្ខរកម្ម គឺជាកូនសោ ជួយឱ្យមានសុខភាពល្អ និងសុខមាលភាព**" សំដៅជួយឱ្យបុគ្គលម្នាក់ៗ និងសង្គមទាំងមូល ទទួលបានសុភមង្គល និងភាពសម្បូររុងរឿង។

ផ្អែកលើទស្សនៈខាងលើនេះហើយដែលទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណាខ្ញុំ ចាត់ទុកវិស័យអប់រំ ជាវិស័យអាទិភាព ហើយដែលក្នុងនោះក៏មានការអប់រំក្រៅប្រព័ន្ធផងដែរ។ កន្លងទៅ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណាខ្ញុំ បានកំណត់ឱ្យមានគោលនយោបាយសម្រាប់ការងារអប់រំក្រៅប្រព័ន្ធ ដោយបង្កើតឱ្យមានកម្មវិធីសកម្មភាពជាអាទិភាពបញ្ចូលផែនការសកម្មភាពការងារនេះទៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផ្តល់គ្រូអក្ខរកម្មជាប់កិច្ចសន្យាជាងមួយពាន់នាក់ ជារៀងរាល់ឆ្នាំ ចំណាយថវិកាមួយចំនួនថែមទៀត សម្រាប់ដោះស្រាយសម្ភារៈទ្រទ្រង់ថ្នាក់រៀន និងការបោះពុម្ពសៀវភៅអក្ខរកម្មជាដើម។

កន្លងមកការងារអប់រំក្រៅប្រព័ន្ធត្រូវបានស្ថាប័ន ក្រសួង មន្ទីរពាក់ព័ន្ធនានា អាជ្ញាធរដែនដីគ្រប់ លំដាប់ថ្នាក់ អង្គការជាតិ អង្គការក្រៅរដ្ឋាភិបាល សមាគម សប្បុរសជន ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យ បព្វជិតសាសនានានា និងប្រជាពលរដ្ឋទាំងអស់ ជួយឧបត្ថម្ភគាំទ្រយ៉ាងសកម្ម។ បងប្អូនប្រជាជនយើង បានឆ្លងផុតពីគ្រោះមិនចេះអក្សររាប់ម៉ឺន រាប់សែននាក់ ព្រមទាំងបានទទួល ការបណ្តុះបណ្តាលមុខរបរ និង បំណិនជីវិត សម្រាប់លើកកម្ពស់ជីវភាព ឱ្យបានកាន់តែ ល្អប្រសើរ។

*-ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ*

*-សម្តេច ទ្រង់ ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោកស្រី អស់លោក*

*-បងប្អូន ជនរួមជាតិជាទីស្នេហា*

ទិវាអក្ខរកម្ម ៨ កញ្ញា ត្រូវបានសន្និបាតអង្គការសហប្រជាជាតិប្រកាសថា ជាទសវត្សរ៍សហប្រជាជាតិ និងជាទសវត្សរ៍នៃការអប់រំសម្រាប់ការអភិវឌ្ឍ ប្រកបដោយស្ថិរភាពចាប់ពីឆ្នាំ ២០០៥ ដល់ ២០១៤ព្រមទាំង បានចាត់ទុកជាភារកិច្ចអន្តរជាតិ សម្រាប់គ្រប់ប្រទេសទាំងអស់ ស្របទៅនឹងគោលដៅនៃវេទិកាពិភពលោកស្តីពីការ អប់រំសម្រាប់ទាំងអស់គ្នា នៅទីក្រុងដាកាប្រទេស សេណេហ្គាល់ ឆ្នាំ ២០០០។

ជាក់ស្តែងចាប់ពីឥឡូវនេះ រហូតដល់ឆ្នាំ ២០១៥ គោលដៅទីក្រុងដាកា នៅតែទាមទារឱ្យអនុវត្តទៅមុខទៀតដោយធានាឱ្យប្រាកដថា **"មានការរីកចំរើនចំនួន ៥០% ក្នុងកម្រិតអក្ខរកម្មជនពេញវ័យនៅមុនដំណាច់ឆ្នាំ ២០១៥ ខាងមុខ"** ជាពិសេសសម្រាប់ស្ត្រីភេទ ផ្តល់ឱកាសស្មើភាពក្នុងការអប់រំមូលដ្ឋាន និងការអប់រំបន្តស្របទៅតាមគោលការណ៍ **"ការអប់រំសម្រាប់ទាំងអស់គ្នា ហើយទាំងអស់គ្នា គឺសម្រាប់ការអប់រំ"** ។

ដើម្បីធ្វើឱ្យសម្រេចគោលបំណងការងារអក្ខរកម្ម ដូចដែលបានកំណត់ក្នុងផែនការជាតិនៃការអប់រំ សម្រាប់ទាំងអស់គ្នា ឆ្លៀតឱកាសដ៏ប្រពៃនេះ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សម្តេច ទ្រង់ ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោកស្រី អស់លោក បងប្អូនជនរួមជាតិទាំងអស់ សូមព្រះមេត្តា និងមេត្តាជួយឧបត្ថម្ភគាំទ្រដល់ការងារអក្ខរកម្មវិជ្ជាជីវៈ ក៏ដូចជាការងារអប់រំក្រៅប្រព័ន្ធដូចតទៅ :

១. សមាជិកសមាជិការាជរដ្ឋាភិបាល ពេលចុះបំពេញការងារតាមមូលដ្ឋាន សូមធ្វើការសាកសួរពី ស្ថានភាពនៃការរៀនសូត្ររបស់ប្រជាជនយើង ហើយបើមានលទ្ធភាពត្រូវឆ្លៀតចុះឱ្យដល់ថ្នាក់អក្ខរកម្ម ដើម្បីលើកទឹកចិត្ត និង ជួយដោះស្រាយនូវរាល់សំណូមពររៀនសូត្រតាមភាពជាក់ស្តែង។

២. គ្រប់វត្តអារាម និង វិហារសាសនានានាត្រូវចលនាព្រះសង្ឃ បព្វជិតសាសនា តាជី ដូនជី លោកអាចារ្យ ចូលរួមជំរុញការងារអក្ខរកម្មតាមរយៈការទេសនា ការឃោសនាអប់រំនៅតាមពិធីបុណ្យផ្សេងៗអំពីសារប្រយោជន៍នៃចំណេះដឹង និង សូមជួយរៀបចំឱ្យមានថ្នាក់អក្ខរកម្ម ឬ មជ្ឈមណ្ឌលសិក្សាសហគមន៍ នៅតាមវត្ត តាមវិហារសាសនា ជូនដល់បងប្អូនកូនចៅ ជាសាសនិកបានរៀនសូត្រគ្រប់ៗគ្នា ។

៣. អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវបង្កើនស្មារតីយកចិត្តទុកដាក់បន្ថែមទៀត ជួយប្រជាជនដែលមិនមានឱកាសរៀនសូត្រ ឱ្យបានរៀនសូត្រតាមគ្រប់រូបភាព និង ជួយគាំទ្រឱ្យបានខ្លាំងក្លាដល់កិច្ចដំណើរការថ្នាក់រៀនអប់រំក្រៅប្រព័ន្ធជាពិសេសថ្នាក់អក្ខរកម្ម ។

៤. មន្ត្រីដឹកនាំអប់រំគ្រប់លំដាប់ថ្នាក់ លោកគ្រូ អ្នកគ្រូត្រូវកំណត់ឱ្យច្បាស់ថា ការងារអប់រំក្រៅប្រព័ន្ធ និងអប់រំក្នុងប្រព័ន្ធ គឺជាដៃគូស្មើភាព មានតួនាទីបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមកក្នុងការផ្តល់ចំណេះដឹងមូលដ្ឋានជូនដល់ប្រជាជន និងត្រូវមានវិធានការប្រើប្រាស់កម្លាំងសមស្រប ដើម្បីជំរុញការងារអក្ខរកម្មឱ្យមានការអភិវឌ្ឍឈានឡើងបានល្អប្រសើរ។

៥. សារព័ត៌មាន វិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី ព្រឹត្តិបត្រព័ត៌មានផ្សេងៗ ទាំងរដ្ឋនិងឯកជន សូមជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសារប្រយោជន៍នៃការរៀនសូត្រ អំពីមុខរបរ និង ចំណេះដឹងផ្សេងៗ ដែលប្រជាជនយើងអាចយកទៅអនុវត្តបានក្នុងជីវភាពប្រចាំថ្ងៃ ។

៦. អង្គការជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល សប្បុរសជនជាតិ និង អន្តរជាតិ សូមបង្កើនការយកចិត្តទុកដាក់ជួយឧបត្ថម្ភគាំទ្រសកម្មភាពអក្ខរកម្មទាំងសម្ភារៈ ថវិកា និង បច្ចេកទេស ដើម្បីជំរុញសកម្មភាពអប់រំក្រៅប្រព័ន្ធនៃប្រទេសយើងខ្ញុំ ឱ្យមានដំណើរការល្អប្រសើរដូចប្រទេសនានានៅក្នុងតំបន់ ។

៧. ប្រធានរោងចក្រ សហគ្រាស ក្រុមហ៊ុនឯកជន សូមជួយជំរុញបើកថ្នាក់អក្ខរកម្មឬថ្នាក់បំប៉នមុខជំនាញផ្សេងៗ ដល់បងប្អូនកម្មករ កម្មការិនី ដើម្បីជាប្រយោជន៍ដល់បងប្អូនកម្មករផង និង ដល់ម្ចាស់រោងចក្រសហគ្រាសផង ។

៨ សិស្សវិទ្យាល័យ និង និស្សិតនៃវិទ្យាស្ថាន និង សាកលវិទ្យាល័យនានាទាំងគ្រឹះស្ថានសិក្សាសាធារណៈ និងទាំងគ្រឹះស្ថានសិក្សាឯកជន សូមចូលរួមសហការដោយស្ម័គ្រចិត្តយ៉ាងសកម្មក្នុងសកម្មភាព អក្ខរកម្មនេះ នៅតាម វត្តអារាម និង មូលដ្ឋាននានានៅទូទាំងប្រទេស ។

៩. បងប្អូនជនរួមជាតិដែលជាអាណាព្យាបាល សូមជួយជំរុញបងប្អូនកូនចៅឱ្យបានចូលរៀននៅតាមសាលារៀនចំណេះទូទៅឱ្យបានគ្រប់ៗគ្នា ។ ឯក្មួយៗ បងប្អូនដែលពុំទាន់ចេះអក្សរ និង អ្នកដែលបានបោះបង់ការសិក្សានៅគ្រប់កំរិតថ្នាក់ សូមខិតខំឆ្លៀតពេលទំនេរពីការរកទទួលទានចូលរៀនតាមថ្នាក់ អក្ខរកម្ម ថ្នាក់បំពេញវិជ្ជា ឬថ្នាក់បំប៉នជំនាញនានា ដែលនៅជិតភូមិឋានរបស់អ្នក ព្រោះចំណេះវិជ្ជា ជាមធ្យោបាយបំភ្លឺផ្លូវឱ្យបងប្អូនចាកផុតពីភាពក្រីក្រ ។ សូមបងប្អូនកូនក្មួយទាំងអស់ចងចាំថា "ការគិតត្រូវ ធ្វើត្រូវ" ទាល់តែមាន ចំណេះដឹងជាមូលដ្ឋាន ។

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណាខ្ញុំ សង្ឃឹមជឿជាក់ថា សេចក្តីអំពាវនាវទាំង៩ចំណុចខាងលើនេះ ពិតជានឹងទទួលបានលទ្ធផលល្អប្រសើរសម្រាប់ជាតិមាតុភូមិយើងនាពេលខាងមុខជាក់ជាពុំខានឡើយ ។

នៅទីបញ្ចប់ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណាខ្ញុំ សូមថ្វាយព្រះពរ ប្រគេនពរ និងជូនពរព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សម្តេច ទ្រង់ ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោកស្រី អស់លោក បងប្អូន ជនរួមជាតិទាំងអស់ សូមសមប្រកប ដោយពុទ្ធពរទាំងប្រាំប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន